**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**អ្នកនាំពាក្យ គ.ជ.ប**
**លេខ ១៦៩ គ.ជ.ប**

ថ្ងៃចន្ទ ៧រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៨

# សេចក្តីប្រកាសព័ត៌មាន
## គ.ជ.ប ផ្តល់សេវាចុះឈ្មោះបោះឆ្នោត នៅតាមឃុំ សង្កាត់ និងនៅតាមភូមិ

ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៨ ដែលមានរយៈពេល ១៨ថ្ងៃ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានរៀបចំឱ្យមានការចុះឈ្មោះនៅតាមឃុំ សង្កាត់ និងនៅតាមបណ្តាភូមិក្នុងឃុំ សង្កាត់ ដោយមានគោលដៅផ្តល់សេវាចុះឈ្មោះបោះឆ្នោត ឱ្យកាន់តែជិតលំនៅឋានប្រជាពលរដ្ឋ។

ក្នុងកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ ស្តីពីការចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់ នីតិវិធីចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ និងការបញ្ជូនទិន្នន័យមក គ.ជ.ប នាថ្ងៃទី១ ខែតុលា ឆ្នាំ២០១៨ ឯកឧត្តម **នុត សុខុម** អនុប្រធាន គ.ជ.ប បានថ្លែងថា “*ក្នុងរយៈពេល ១៨ថ្ងៃនេះ យើងបានកំណត់ទៅតាមផែនការនៃការចុះឈ្មោះបោះឆ្នោតគឺ ៥ថ្ងៃដំបូង យើងចុះឈ្មោះនៅសាលាឃុំ សង្កាត់ ហើយ ៩ថ្ងៃ យើងទៅចុះឈ្មោះនៅតាមបណ្តាភូមិ ហើយនិង ៤ថ្ងៃចុងក្រោយ គឺយើងមកចុះឈ្មោះនៅសាលាឃុំ សង្កាត់វិញ*” ។ ឯកឧត្តមបានបន្ថែមទៀតថា ការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៨ ត្រូវធ្វើឡើងសម្រាប់ប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោត ហើយពុំទាន់បានចុះឈ្មោះបោះឆ្នោតពីមុនមក និងប្រជាពលរដ្ឋ ដែលទើបគ្រប់អាយុ ១៨ឆ្នាំ (កើតមុន ឬកើតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០០១) ។

ចំពោះការចុះឈ្មោះប្រជាពលរដ្ឋ ដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចូលក្នុងឃុំ សង្កាត់ថ្មី ត្រូវបង្ហាញខ្លួននៅចំពោះមុខក្រុមចុះឈ្មោះបោះឆ្នោតនៃឃុំ សង្កាត់ថ្មី ដើម្បីរាយការណ៍សុំលុបឈ្មោះនៅឃុំ សង្កាត់ចាស់ និងបំពេញបែបបទសុំចុះឈ្មោះបោះឆ្នោតជាថ្មី។ ក្រុមចុះឈ្មោះបោះឆ្នោត នឹងអនុវត្តតាមនីតិវិធីនៃការផ្ទេរទិន្នន័យរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត ពីការិយាល័យបោះឆ្នោតនៃឃុំ សង្កាត់ចាស់ មកការិយាល័យបោះឆ្នោតនៃឃុំ សង្កាត់ថ្មីវិញ ។

សូមជម្រាបជូនថា ភាគីពាក់ព័ន្ធដែលបានចូលរួមក្នុងកិច្ចប្រជុំនៅថ្ងៃនេះរួមមាន ៖ តំណាងក្រុមប្រឹក្សាធម្មនុញ្ញ ក្រសួងមហាផ្ទៃ ក្រសួងព័ត៌មាន តំណាងស្ថានទូតជប៉ុន តំណាងអង្គការមិនមែនរដ្ឋាភិបាលចំនួន ១១ តំណាងគណបក្សនយោបាយ ចំនួន ១០ អង្គភាពសារព័ត៌មានចំនួន ៨ សរុបចំនួន ៥០នាក់។

ព្រឹត្តិការការណ៍ ធ្វើឡើងដោយអនុលោមតាមសិទ្ធិចុះឈ្មោះបោះឆ្នោត ដូចមានចែងក្នុងមាត្រា ៣៤ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៤៦ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ៕

**ចំពោះព័ត៌មានពិស្តារ សូមទាក់ទង!**


| | |
|---|---|
| ឯកឧត្តម **ហង្ស ពុទ្ធា** សមាជិក និងជាអ្នកនាំពាក្យ គ.ជ.ប | ឯកឧត្តម **ឌឹម សុវណ្ណារុំ** សមាជិក និងជាអ្នកនាំពាក្យ គ.ជ.ប |
| Tel: (855)12 959 666 | Tel: (855)12 518 485 |
| Email : hangputhea@gmail.com | Email : sovannaromhy@yahoo.fr |